# វគ្គបណ្ដុះបណ្ដាល
# ស្ដីពី
# សុវត្ថិភាពឧស្សាហកម្ម

នៅព្រឹកថ្ងៃសុក្រ ២រោច ខែមាឃ ឆ្នាំរកា នព្វស័ក ព.ស ២៥៦១ ត្រូវនឹងថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០១៨ ឯកឧត្តម **គោគ សុវណ្ណារិទ្ធ** រដ្ឋលេខាធិការ តំណាងដ៏ខ្ពង់ខ្ពស់ ឯកឧត្តម **ចម ប្រសិទ្ធ** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម បានអញ្ជើញជាអធិបតី ក្នុងពិធីបើកវគ្គបណ្ដុះបណ្ដាល ស្ដីពី សុវត្ថិភាពឧស្សាហកម្ម នៅសាលប្រជុំរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ។

វគ្គបណ្ដុះបណ្ដាលនេះធ្វើឡើងក្នុងគោលបំណងចែករំលែកចំណេះដឹង និងបទពិសោធន៍ ស្ដីពីការគ្រប់គ្រង ការថែទាំ ការត្រួតពិនិត្យ និងផ្សព្វផ្សាយពីបទបញ្ញត្តិនានា នៃការគ្រប់គ្រងគ្រឿងចក្រគ្រឿងម៉ាស៊ីន ដែលមានហានិភ័យក្នុងរោងចក្រ សិប្បកម្ម ជូនវិស័យឯកជន ជាពិសេសដល់កម្មករ អ្នកបញ្ជាឡចំហាយ អ្នកបញ្ជាគ្រឿងចក្រ គ្រឿងម៉ាស៊ីន ដែលមានហានិភ័យឲ្យបានយល់ដឹងពីការគ្រប់គ្រងសុវត្ថិភាព និងប្រសិទ្ធិភាព ក្នុងការអនុវត្តន៍ការងារឲ្យបានសមស្របតាមលក្ខណៈបច្ចេកទេស ដើម្បីបញ្ចៀស និងបង្ការគ្រោះថ្នាក់ដែលអាចកើតមានឡើងនៅកន្លែងផលិតកម្ម ធ្វើឲ្យបាត់បង់អាយុជីវិតកម្មករ និងខូចខាតទ្រព្យសម្បត្តិសារធារណៈ ដើម្បីជានាឲ្យបាននូវការអភិវឌ្ឍប្រកបដោយចីរភាព។ វគ្គបណ្ដុះបណ្ដាលនេះមានសិក្ខាកាមចូលរួមចំនួនសរុប ៩៩រូប មកពីរោងចក្រចំនួន២៣ នៅរាជធានីភ្នំពេញ ខេត្តកណ្ដាល ខេត្តកំពង់ស្ពឺ ខេត្តកំពង់ឆ្នាំង និងខេត្តតាកែវ។

សិក្ខាសាលាបណ្ដុះបណ្ដាលនេះបានបញ្ចប់នៅវេលាម៉ោង ១៧ : ០០ នាទីរសៀលនាថ្ងៃខែឆ្នាំដដែល ព្រមទាំងមានការចែកជូននៅវិញ្ញាបនប័ត្រជូនសិក្ខាកាមដែលបានចូលរួមវគ្គបណ្ដុះបណ្ដាលនេះផងដែល ដោយប្រកបដោយភាពស្និតស្នាល និងមានការទទួលខុសត្រូវខ្ពស់។




TRAINING COURSE
BTV






TRAINING COURSE
ON
INDUSTRIAL SAFETY